# ទស្សនៈកិច្ចសិក្សារបស់កសិករជនជាតិដើមភាគតិច នៅខេត្តកំពត

នៅថ្ងៃទី ២០ ដល់ ២២ ខែ មីនា ឆ្នាំ ២០០៩ មានកសិករជានជាតិដើមភាគតិចមួយក្រុម ដែលមានគ្នាប្រមាណ ២០ នាក់ (ជនជាតិព្នង ) មកពីគំរោងកសិកម្មចិញ្ចឹមជីវិត នៅខេត្តមណ្ឌលគីរី ធ្វើទស្សនៈកិច្ចសិក្សានៅខេត្តកំពត ។ ចាប់តាំងពីពួកគេបានរៀនចេះខ្លះៗ ទាក់ទងទៅនឹងការបង្កើត សមាគមកសិករតាមភូមិដែលបានបណ្តុះបណ្តាលដោយបុគ្គលិកគំរោងអង្គការ សេដាក នៅខេត្តមណល គីរីរួចមក ។ ទស្សនៈកិច្ចសិក្សានេះត្រូវបាន សំរបសំរួលដោយបុគ្គលិកគំរោង លោកជៀវ សុភ័ត្រ ។

កសិករបានទស្សនា និងពិភាក្សាអំពីបញ្ហាបញ្ចុប្បន្ន ជាមួយអ្នកដឹកនាំ ដែលមានជំនាញមកពីសមាគម កសិករតាមភូមិនៅខេត្តកំពត ។ ពួកគាត់ បានយល់យ៉ាងច្បាស់អំពីផលប្រយោជន៍របស់សមាគម កសិករតាមភូមិ ក៏ដូចជាដំណើរការ និងតំរូវការ ព្រមទាំងវិធីសាស្ត្របង្កើតសមាគមកសិករតាមភូមិ ។

គួរកត់សំគាល់ថា ពួកគេក៏បានទៅទស្សនា និងជួបពិភាក្សាជាមួយលោកអួន សុផល ប្រធានបណ្តាញ កសិករ និងធម្មជាតិ ។ វាគឺជាឳកាសដ៏ល្អមួយសំរាប់ពួកគាត់ ដើម្បីសិក្សាពីគ្រូបង្គោលរបស់សមាគម កសិករតាមភូមិ ។ នៅខណៈនោះដែរច្បាប់របស់សមាគមកសិករក៏ត្រូវបានពិនិត្យនិងពិភាក្សា ។ ការអនុវត្តបច្ចេកទេស និងវិធីសាស្ត្រប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ (ប.វ.ស) ក៏ត្រូវបានលើកយកមក បង្ហាញផងដែរដោយកសិករអ្នករៀបចំ ។ សេដាក ជឿជាក់ថា នឹងមានកសិករជនជាតិដើមភាគតិច កាន់តែច្រើនថែមទៀត អនុវត្តនូវវិធីសាស្ត្រ ប.វ.ស នៅរដូវធ្លាក់ភ្លៀងខាងមុខនេះ ។

ឆ្លងតាមទស្សនៈកិច្ចសិក្សានេះ កសិករជនជាតិដើមភាគតិច មានចំណាប់អារម្មណ៍ចង់បង្កើតសមាគម កសិករតាមភូមិ នៅក្នុងឃុំសុខសាន្ត ស្រុកកោះញែក ខេត្តរតនៈគីរីរបស់ពួកគាត់ ។ សង្ឃឹមថា សមាគម កសិករជនជាតិដើមភាគតិច នឹងបង្កើតឡើងបន្ទាប់ពីដំណើរទស្សនៈកិច្ចសិក្សាប្រកបដោយ ជោគជ័យ ។

